ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## " ការដាក់ឲ្យដំណើរការប្រព័ន្ធពង្រឹងសមត្ថភាព និងតេស្តសមត្ថភាពដោយខ្លួនឯង សម្រាប់សិស្សថ្នាក់ទី១២ លើប្រព័ន្ធអ៊ីនធើណែត "

ក្រសួងអប់រំ យុវជន និងកីឡា មានកិត្តិយស សូមជម្រាបជូនសាធារណជន ពិសេសសិស្សានុសិស្សថ្នាក់ទី១២ មេត្តាជ្រាបថា៖ លើមូលដ្ឋាននៃការអនុវត្តកំណែទម្រង់ក្នុងវិស័យអប់រំ យុវជន និងកីឡា តាមរយៈការបង្កើនគុណភាពការបង្រៀន និងការរៀន ក្រសួងបានបង្កើតប្រព័ន្ធសិក្សាពីចម្ងាយ (E-Learning Management System) ដែលអនុញ្ញាតឲ្យសិស្សានុសិស្សថ្នាក់ទី១២ ប្រើប្រាស់ពេលវេលាទំនេរពីការសិក្សាក្នុងថ្នាក់ ដើម្បីឆ្លើយសំណួរ ឬធ្វើលំហាត់លើមុខវិទ្យា គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងប្រវត្តិវិទ្យា តាមប្រព័ន្ធអនឡាញ (On-line) ដោយអាចប្រើប្រាស់ **ទូរស័ព្ទស្មាតហ្វូន Tablet ឬកុំព្យូទ័រ** ។ ប្រព័ន្ធនេះនឹងជួយពង្រឹងសមត្ថភាពរបស់សិស្សានុសិស្ស មួយកម្រិតថែមទៀត លើចំណេះដឹងដែលទទួលបានពីលោកគ្រូ អ្នកគ្រូនៅក្នុងថ្នាក់រៀន។ ក្រសួងអប់រំ យុវជន និងកីឡា នឹងប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៧ នៅទីស្តីការក្រសួងអប់រំ យុវជន និងកីឡា វេលាម៉ោង ០៨:០០ នាទីព្រឹក។ បន្ទាប់ពីការដាក់ឲ្យប្រើប្រាស់ជាផ្លូវការ សិស្សានុសិស្សអាចអនុវត្តកម្មវិធីនេះបានតាមរយៈតំណភ្ជាប់នៅលើគេហទំព័រក្រសួង: bacii.moeys.gov.kh ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១៧

ក្រសួងអប់រំយុវជននិងកីឡា